# មង្គល៣៨ប្រការ

(ដកស្រង់ប្រែសម្រួលពីភាសាអង់គ្លេស - បទពាក្យ៧ )

*នាពេលមួយនោះ អង្គព្រះភគវន្ត  គង់វត្តជេតពនក្រុងសាវត្ថី*
*អារាមអនាថបិណ្ឌិកសេដ្ឋី  រាល់ទិវារាត្រីក្នុងកុដិសុគន្ធ ។*
*នាអាធ្រាត្រនោះ មានទេពធីតា  រស្មីអស្ចារ្យបំភ្លឺជេតពន*
*សុគន្ធកុដិលុតថ្វាយបង្គំ  លើកហត្ថប្រណម្យ ព្រះអង្គគង់នៅ ។*
*បង្គំរួចហើយ ឈរស្ងៀមធម្មតា  ចាំព្រះសាស្តាទ្រង់ត្រាស់ប្រដៅ*
*កាលវេលាល្អក៏ខិតចូលទៅ  ជិតអង្គឆោមឆ្មៅ ហើយថ្លែងទូលថា ៖*

*មនុស្សនិងទេវតា ស្វែងរកមង្គល  សូមព្រះទសពលពន្យល់អស់អាថ៌*
*អត្ថន័យសេចក្តីប្រណីមេត្តា  ត្បិតយើងរាល់គ្នា មិនអស់ចម្ងល់ ។*

*ព្រះអង្គតុណ្ហី ([1]) ត្រាស់សំដែងប្រាប់  ចូរនាងចាំស្តាប់ តថាគតពន្យល់*
*ស្តាប់ហើយអនុវត្ត ទើបបានលទ្ធផល  នេះគឺមង្គលសាមប្រាំបីប្រការ ។*

*មង្គលទី១ គឺធម៌សេពគប់  អ្នកកុំប្រសព្វនឹងជនពាលា*
*មង្គលទី២សេពគប់អ្នកជា  អ្នកមានប្រាជ្ញា អាចារ្យ បណ្ឌិត ។*
*មង្គលទី៣ របៀបបូជា  គួរពិចារណាខំត្រិះរិះគិត*
*បូជាបុគ្គលគួរបូជាពិត  បុគ្គលល្អល្អិត ស្ថិតក្នុងសំណួរ ([2])។*
*មង្គលទី៤ ប្រទេសកន្លែង  ត្រូវខំខ្នះខ្នែងរើសឲ្យសមគួរ*
*កន្លែងរស់នៅមិនត្រូវអាប់អួរ  នាំឲ្យហ្មងហ្មួរដួរដល់គេឯង ។*
*មង្គលទី៥ បុណ្យពីបុព្វេ  បានធ្វើហូរហែហុចផលជាក់ស្តែង*
*មង្គលទី៦តម្កល់ខ្លួនឯង  អ្នកកុំសំដែងឲ្យគេមើលងាយ ។*

1ភាពស្ងប់ស្ងៀមទាំងកាយ ទាំងវាចា និងទាំងចិត្ត
2 គឺការពិចារណាត្រិះរិះសួររកហេតុផល

មង្គលទី៧ ពាហុសច្ចៈ ([3])
រៀនសូត្រឲ្យជាក់ ផ្ទាក់ជាសំពាយ
រៀនច្រើនកើតច្រើន កើនចំរើនងាយ
មុខរបរក្វាយ ជាមង្គលទី៨ ។
មង្គលទី៩ វិន័យបញ្ញត្តិ
អ្នកត្រូវអនុវត្ត គោរពសម្តី
មង្គលទី១០ ការនិយាយស្តី
ពោលពាក្យរៃងខ្ទី មធុរវាចា ([4])។
មង្គលទី១១ ត្រូវជួយឧបត្ថម្ភ
រក្សាថែទាំ មាតាបិតា
មង្គល១២ បុត្រីបុត្រា
ប្រពន្ធប្តីត្រូសារ ត្រូវចេះសង្គ្រោះ ។
មង្គល១៣ អនាកុលា ([5])
ប្រកបការងារកុំឲ្យជ្រុលជ្រួស
ច្របូកច្របល់ត្រូវគេចឲ្យហួស
ត្រូវដឹងទាបខ្ពស់ក្រែងគ្រោះទុក្ខភ័យ ។
មង្គល១៤គឺការធ្វើទាន
ផលបុណ្យប៉ុន្មានទាំងចាស់ទាំងថ្មី
បើចេតនាល្អមិនរង់ចាំអ្វី
ព្រះធម៌លកលែតម្លៃតាមនោះ ។
មង្គល១៥ធម្មចរិយា
កាយចិត្តវាចាក្នុងសីលឥតខ្ចោះ
មង្គល១៦ញាតិសន្តាននោះ
ត្រូវចេះសង្គ្រោះថែទាំរក្សា ។
មង្គល១៧ការងារឥតទោស
ប្រកាន់យកចុះវាជួយអាត្មា
យកសុខទៅមុខសំអាតសង្ខារ
កាយចិត្តវាចា រហូតបរលោក ([6])។
មង្គល១៨ ត្រូវចេះខ្លាចបាប
ធ្លាក់ដល់ស្ថានទាបនាំខ្លួនឲ្យថោក
យកសីលជាគោលទើបផុតក្តីសោក
តាំងពីបរលោកដល់សួគ៌និព្វាន ។
មង្គល១៩ ត្រូវចៀសវាងបាប
ទី២០បន្សាបបន្ថយគ្រឿងញៀន
បារីម្សៅស្លាកញ្ញាអាភៀន
ស្រាបៀរ ([7])ប៉ុន្មាននាំមានកម្មពៀរ ។
មង្គល២១ អ្នកកុំប្រមាទ ([8])
ធ្វេសប្រហែសខាតធ្លាក់ចូលអវិជ្ជា
មានសតិដឹងអាណាបាណា ([9])
ដង្ហើមវេទនាសង្ខារចាស់ថ្មី ។
មង្គល២២ គោរពគារវៈ
បង្អោនកាយដាក់ជាមង្គល២៣

---

3 ការខិតខំរៀនសូត្រយ៉ាងឧិហាតទាំងយប់ទាំងថ្ងៃ

4 មធុរ ៖ ទឹកឃ្មុំ , មធុរវាចា ៖ សំដីពិរោះបរិសុទ្ធចេញពីទឹកចិត្តមេត្តា មានរសជាតិផ្អែមដូចទឹកឃ្មុំ

5អានថា ៖ អាក់ណាកុឡា , ភាពមិនច្របូកច្របល់ អន្ទះអន្ទែង

6 អានថា ៖ បរឡោក , លោកឬស្ថានក្រោយពីសេចក្តីស្លាប់

7 Beer ខ្មែរហៅថា ស្រាបៀរឬ ឡាបយ៉េ (la bierre)

8 ប្រមាទ ៖ ធ្វេសប្រហែស , ប្រមាថ ៖ មើលងាយ (superiority complex)

9 អាណ: ៖ ដង្ហើមចូល (inspiration ) + អាបាណ: ៖ ដង្ហើមចេញ (expiration) អាណាបាណ: ៖ ការពិនិត្យដង្ហើមចូលដង្ហើមចេញតាមធម្មជាតិ

មង្គល២៤របស់ក្នុងដៃ ស្រឡាញ់លក់លៃថែទាំរក្សា ។
មង្គល២៥ត្រូវចេះដឹងគុណ អ្នកឲ្យពីមុនធម៌កតញ្ញូតា ([10])
តបស្នងសងគុណកតវេទិតា ([11]) កំណត់កត់ត្រាចងចាំទាំងអស់ ។
មង្គល២៦ធម្មសវនំ ([12]) ចិត្តសទ្ធាខ្ជាំងស្តាប់ធម៌ដោយស្មោះ
សង្វាតសូត្ររៀនវចនៈទាំងអស់ នាំអ្នកឲ្យខ្ពស់ហួសដល់វិជ្ជា ។
មង្គល២៧រក្សាខន្តី អត់ឱនប្រណីដល់សត្វផងគ្នា
មង្គល២៨ស្តាប់តាមគ្រប់គ្រា ពាក្យប្រដៅថារបស់បណ្ឌិត ។
មង្គល២៩ជីវភាពសមណៈ ជាសង្ឃសាវ័កក្នុងសាសនាពិត
បំពេញនេក្ខម្មៈ ([13])ស្ម័គ្រសំអាតចិត្ត ឲ្យដល់កំរិតក្នុងភេទជាសង្ឃ ។
មង្គល៣០ធម្មសាកច្ឆា ([14]) ជជែកធម៌អាថ៌ប្រណាម្យកំបង់
តាមកាលវេលាដោយចិត្តស្មោះត្រង់ រួចមិនបោះបង់អសារឥតការ ។
មង្គល៣១ការបដិបត្តិធម៌ តបៈ ([15])ឲ្យល្អតាមពុទ្ធដីកា
មង្គល៣២ព្រហ្មចរិយា រៀនវិបស្សនាលះកាមច្ឆន្ទៈ ([16])។
មង្គល៣៣អរិយសច្ច៤ ពិសោធក្នុងខ្លួនឲ្យឃើញជាក់លាក់
មង្គល៣៤និព្វានសច្ចៈ ពិសោធប្រត្យ័ក្ស ([17])ក្នុងកាយនេះហើយ ។
មង្គល៣៥ធម៌ឧបេក្ខា ចិត្តនេះកាលណាលោកធម៌ ([18])ប៉ះហើយ
នកម្បតិ មិនញាប់ញ័រឡើយ ត្រង់នេះឯងហើយមង្គលឧត្តម ([19])។
មង្គល៣៦ធម៌ឧបេក្ខា ចិត្តនេះកាលណាលោកធម៌ប៉ះហើយ

10 ការដឹងគុណ

11 ការតបស្នងសងគុណបន្ទាប់ពីបានពិចារណាដឹងគុណគេរួចហើយ

12 អានថា ធាំមាក់សាក់វាក់ណាំង ៖ ការស្តាប់ធម៌ពិត

13 អានថា ៖ នេខាំមាក់, ការលះបង់ជីវភាពជាមេផ្ទះទៅបួសជា សមណៈឬដូនជី

14 អានថា ៖ ធាំមាក់សាកាច់ឆា , ការជជែកវែកញែកអំពីធម៌តាមកាលវេលា

15 អានថា ៖ តាក់ប៉ាក់ , ការប្រឹងប្រែងទាញសតិមករកកម្មដ្ឋានត្រូវ

16 អានថា ៖ កាមម៉ាច់ឆាន់ទាក់, ឆន្ទៈប្រាថ្នារិះរកកាមបណ្តាលមកពីរូប,សម្លេង,ក្លិន,រស និង សម្ផស្ស (ការប៉ះពាល់)

17អានថា ៖ ប្រត្យាក់, ភាពពិតប្រាកដ

18 លោកធម៌គឺការប្រែប្រួលវិបល្លាសក្នុងជីវិត មាន៨យ៉ាងគឺ ៖ លាភ, អលាភ, យស, អយស, សរសើរ, និន្ទា, សុខ និង ទុក្ខ ។ ទោះបីគេជួបប្រទះនឹង លោកធម៌៨យ៉ាងនេះក៏ដោយ មង្គលនឹងមានចំពោះអ្នកដែលមានចិត្តឧបេក្ខា ។

19 មិនចាប់ចុងជូនទេ ពីព្រោះចង់រក្សាឃ្លាដើមឲ្យនៅដដែល ។

ចិត្ត អសោកំ មិនសោកសៅឡើយ ត្រង់នេះឯងហើយមង្គលឧត្តម ។
មង្គល៣៧ធម៌ឧបេក្ខា ចិត្តនេះកាលណាលោកធម៌ប៉ះហើយ
ចិត្ត វិរជំ មិនសៅហ្មងឡើយ ត្រង់នេះឯងហើយមង្គលឧត្តម ។
មង្គល៣៨ធម៌ឧបេក្ខា ចិត្តនេះកាលណាលោកធម៌ប៉ះហើយ
ជាចិត្ត ខេមំ ក្សេមក្សាន្តឥតត្រើយ ត្រង់នេះឯងហើយមង្គលឧត្តម ។

បើអនុវត្តតាមរបៀបនេះឯង គ្រប់ទីកន្លែងអ្នកបានជោគជ័យ
គ្រប់ទីកន្លែងអ្នកសប្បាយក្រៃ នេះជាអត្ថន័យមង្គលឧត្តម ។

យោបល់អ្នកនិពន្ធ ៖

នេះធម៌អនុវត្ត បរិស័ទប្រុសស្រី បានយល់សេចក្ដីគាថាព្រះបរម
ជាធម៌បដិបត្តិមិនមែនសូត្រផ្ទុំ មង្គលឧត្តមកើតដោយសាច់ការ ។
ព្រះបរមសាស្ដាត្រាស់ឲ្យយើងធ្វើ មិនមែនទង្វើរបស់អាចារ្យ
បាយសីស្រោយទឹក ([20])ចងខ្សែគាថា សូត្រមន្តសីមាមិនបានការទេ ។
តុម្ហេហិ កិច្ចំ អាតាបំ បដិបត្តិក្លាខ្លាំងកុំនៅទំនេរ
ខ្លួនអ្នកនេះហើយមិនមែនគេទេ ចូរគិតរិះរេឲ្យបានហ្មត់ចត់ ។
អក្ខាតារោ តថាគតា នេះជាគាថាព្រះសម្មាសម្ពុទ្ធ
តថាគតប្រាប់ផ្លូវឲ្យអ្នកចេញផុត ពីមហាសមុទ្រទុក្ខអ្នកដើរខ្លួនឯង ។

20 សម័យឥឡូវនេះមានគ្រូមន្តអាគមខ្លះប្រើទុយោបាញ់ទឹកជំនួសការដងផ្ដិលស្រោច ។